អង្គការរ៉ឺម៉កកង់បី សម្រាប់កុមារ R4C

**សកម្មភាព** ៖ ល្បែងល្ខោនអាយ៉ងម្រាមដៃ

**ចិត្តចលភាព៖**

បំណិនចលករតូច៖ កាហ្វឹកហាត់បង្កើនកម្លាំងនិងសម្របសម្រួលរវាងចលនាសាច់ដុំដៃ និងសាច់ដុំភ្នែក។

**គោលបំណង៖**

វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបធ្វើចលនាដៃតាមទម្រង់ផ្សេងៗដោយធ្វើការជាមួយអ្វីមួយ និងការលេងល្បែងអ្វីមួយ។

**សិក្សាសង្គម៖**

បំណិនទំនាក់ទំនង៖ បំណិនរស់នៅក្នុងសង្គមនិងទំនាក់ទំនងវិជ្ជមានជាមួយមនុស្សជុំវិញខ្លួន

**គោលបំណង៖**

បំណិនសម្បទា៖ រៀបរាប់និងប្រាប់បានពីឈ្មោះមនុស្សជុំវិញខ្លួនឱ្យជួយនៅពេលដែលខ្លួនមានបញ្ហា

គំនូរនិងសកម្មភាពកសាង៖ ការយល់ដឹងនិងពេញចិត្តចំពោះសិល្បៈតាមរយការបង្កើតជារូបភាពផ្សេងៗ

វិជ្ជាសម្បទា៖ ប្រាប់បានពីរបៀបបត់ រោយ ដេរ ត្បាញ សូនរូប ផាត់ពណ៌ ហែក បិទ បត់ កាត់… ដើម្បីបង្កើតជារូបភាពផ្សេងៗ។

**រយៈពេល** ៖ ៣០ នាទី

**ឧបករណ៍** ៖ ក្រដាសដែលមានរូបសមាជិកគ្រួសារ (អ្នកអាចទាញយកនៅក្នុងគេហទំព័ររបស់អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារបាន👉https://rermork.org)

ក្រដាសសឬក្រដាសពណ៌ក៏បានដែរ តាមការចូលចិត្តរបស់អ្នក កន្ត្រៃ កាវស្អិត

**កម្រិតសិក្សា** ៖ ទាប មធ្យម និងខ្ពស់

**ការរៀបចំ** ៖ រៀបចំសម្ភារមួយឈុត សម្រាប់បង្ហាញទៅកាន់កុមារ។

**សេក្តីណែនាំ៖**

1. សួរកុមារនូវសំណួរខ្លះៗដែលទាក់ទងនឹងសមាជិកគ្រួសារ ដូចជា៖ តើកូនៗមានគ្រួសារដែរឬទេ? គ្រួសាររបស់កូនៗមានអ្នកណាគេខ្លះ? ចូលកូនៗរៀបរាប់ផង។
2. បង្ហាញសម្ភារដែលអ្នកបានរៀបចំមួយឈុតនោះ ទៅកាន់កុមារ សមាជិកគ្រួសារមានអ្នកណាខ្លះ…។
3. ចាប់ផ្តើមប្រាប់កុមារពីរបៀបធ្វើវាជាមុនសិន។
   - ➔ កាត់រូបសមាជិកគ្រួសារមុន។

- ➔ កាត់ក្រដាសសឬក្រដាសពណ៌នោះទំហំឱ្យប៉ុនម្រាមដៃទាំង៥នៅពេលដែលបិទវាជារង្វង់រួច ។
- ➔ កាត់ក្រដាសសឬក្រដាសពណ៌ឱ្យល្មមនឹងម្រាមដៃរបស់កុមារ បន្ទាប់មកបិទជារង្វង់ប៉ុនម្រាមដៃទាំង៥។
- ➔ បន្ទាប់មកយកក្រដាសរូបភាពដែលកាត់រួចមកបិទនៅផ្នែកខាងលើក្រដាសពណ៌ដែលអ្នកបានបិទជារង្វង់ទំហំប៉ុនម្រាមដៃនោះ នៅផ្នែកខាងមុខបាតដៃនៃផ្នែកម្រាមដៃ។

4. នៅពេលដែលធ្វើរួច ចាប់ផ្តើមលេង ដោយឱ្យកុមារបានស្គាល់សមាជិកគ្រួសារ ដោយឱ្យពួកគេលេងម្តង៥នាក់ ដូច្នេះត្រូវត្រៀមសម្ភារ៥ឈុតដែរ។
5. ឱ្យពួកគេពាក់រូបសមាជិកគ្រួសារ ឱ្យបានគ្រប់ៗគ្នា។
6. ឱ្យពួកគេឡើងទៅឈរនៅមុខក្តារខៀន។
7. គ្រូស្រែកពាក្យថា ឪពុក កុមារត្រូវលើកម្រាមដៃឪពុក នៅពេលដែលស្រែកពាក្យថា ម្តាយ កុមារត្រូវលើកម្រាមដៃដែលមានសមាជិកម្តាយ។
8. នៅពេលលេងប្រសិនបើកុមារណាដែលលើកម្រាមដៃត្រូវនឹងក្លាយជាអ្នកឈ្នះ រីឯកុមារដែលលើកម្រាមដៃខុស គឺនឹងក្លាយជាអ្នកចាញ់។
9. លេងបែបនេះឱ្យបានគ្រប់គ្នា គឺជាការស្រេចតែម្តង។

**ការប្រែប្រួល៖**

- ❖ របៀបធ្វើសម្ភារសម្រាប់លេងល្បែងនេះមានច្រើនប្រភេទ អ្នកអាចស្វែងរកវិធីណាដែលងាយស្រួលសម្រាប់អ្នកក៏បានដែរ។ សម្រាប់ល្បែងនេះយើងបានជាបទចម្រៀងសម្រាប់ច្រៀងនៅពេលដែលកំពុងលេងបានដែរ ប្រសិនបើអ្នកត្រូវការវា។ អាចចូលទៅក្នុងវេបសាយ ឬគេហទំព័រ និងយូធូបរបស់ខាងអង្គការរ៉ីម៉កកង់សម្រាប់កុមារបានផងដែរ។
  - ➢ បទចម្រៀង គ្រួសារម្រាមដៃ
  - ➢ បទចម្រៀង គ្រួសារម្រាមដៃ (តុក្កតា)